ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅឆ្នាំ២០១៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការបង្កើនផលិតភាព ពិពិធកាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីរួមចំណែក អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា។ ជាពិសេសការខិតខំបង្វែរទិសដៅនៃការអភិវឌ្ឍតាមបែបវិបុលកម្មឆ្ពោះទៅកាន់ការអភិវឌ្ឍតាមបែបប្រពលវប្បកម្មតាមរយៈការធ្វើកសិកម្មចម្រុះឱ្យអស់លទ្ធភាព ហើយក៏ជារបៀបវារៈមួយដ៏សំខាន់ដែលក្រសួងបានណែនាំទៅដល់គ្រប់អង្គភាពជំនាញទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

នៅក្នុងឆ្នាំ២០១៦នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាត្រូវបានបញ្ចប់ជាស្ថាពរហើយៗប្រជាកសិករបាននិងកំពុងខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម និងជំរុញការងារដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀតយ៉ាងសស្រាក់សស្រាំ ជាពិសេសការបង្កបង្កើនផលស្រូវរដូវប្រាំងរួមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មផងដែរ។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើង ៩១,១៧% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របី ៨,៨៣% ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ទន្ទឹមនឹងនោះ ក្រសួងក៏បានចាត់អង្គភាពជំនាញដែលជាសេនាធិការក្នុងការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀត ជាពិសេសបទល្មើសព្រៃឈើដោយបន្តកិច្ចសហការជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ (សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦) ព្រមទាំងបទល្មើសជលផល (សេចក្តីសម្រេចលេខ១២៨សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦) បទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈព្រមទាំងជំរុញការងារផ្សព្វផ្សាយកសិកម្មយ៉ាងសកម្មផងដែរ ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម។

គួរសម្គាល់ផងដែរថា ក្នុងឆ្នាំ២០១៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានទទួលជួបគណៈកម្មការទី៣នៃរដ្ឋសភា (គណៈកម្មការផែនការ និងវិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទបរិស្ថាន និងធនធានទឹកនៃរដ្ឋសភា) និងគណៈកម្មការទី១០នៃព្រឹទ្ធសភា (គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃនៃព្រឹទ្ធសភា) ដើម្បីស្វែងយល់ និងដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្ម រួមទាំងការទទួលជួបសវនាការជាមួយអង្គទូត និងដៃគូរអភិវឌ្ឍន៍ រួមទាំងការចូលរួមកិច្ចប្រជុំសំខាន់ៗនៅក្រៅប្រទេសជាច្រើនផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០១៦នេះ មានដូចតទៅ៖



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សាឆ្នាំ២០១៦

ការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៦ ត្រូវបានបញ្ចប់ជាស្ថាពរហើយដែលមានទិន្នន័យលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ ក្របីមានចំនួន ២៦៥ ១០២ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧៣៥ ៩៨៣ហ.ត តិចជាងឆ្នាំមុនចំនួន ៥៥២ ៨០២ហ.ត គិតក្នុងរយៈពេលដូចគ្នា
- ផ្ទៃដីសាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុនចំនួន ២០ ៨៥៨ហ.ត
- ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ២ ៥៩៩ ៥៨៦ហ.ត ស្មើនឹង ១០៤,៩៧% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុនចំនួន ៣៧ ៦២៩ហ.ត
- ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ២ ៣១៥ ៧៩៤ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៩ ៥៨៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៦ ៨៥៧ ៨០៧តោន លើសឆ្នាំមុន ៦០៨ ៣៩៨តោន។ ទិន្នផលគិតជាមធ្យម ២,៩៦១តោន/ហ.ត លើសឆ្នាំមុន ២២១គ.ក្រ/ហ.ត។

#### ១.២ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣៦៩ ៣០៥ហ.ត តិចជាងឆ្នាំមុនចំនួន ១០៩ ៣៨៥ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ១២ ៥៩៩ហ.ត និងដោយគ្រឿងយន្តមានចំនួន ៣៥៦ ៧០៥ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៤៤៣ហ.ត តិចជាងឆ្នាំមុនចំនួន ៦៨៨ហ.ត
- ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ៣០៧ ៥០១ហ.ត ស្មើនឹង ៧០,៨៩% នៃផែនការ ៤៣៣ ៧៥៥ហ.ត តិចជាងឆ្នាំមុនចំនួន ១១២ ០៩៤ហ.ត (មូលហេតុដោយទឹកស្រកឃើត)។

#### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំង

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៤៤ ៦៣៥ហ.ត តិចជាងឆ្នាំមុនចំនួន ៥ ១៨២ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៨ ៧០៣ហ.ត ស្មើនឹង ៥២,៨៤% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុនចំនួន ២ ២០៩ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥ ៩៣២ហ.ត ស្មើនឹង ៤២,០១% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុនចំនួន ១ ៩៧៣ហ.ត។

#### ១.៤ ការនាំចេញអង្ករ

ក្នុងរយៈពេល១២ខែដើមឆ្នាំ២០១៦នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៥៤២ ១៤៤តោន ដែលមានការកើនឡើងចំនួន ៣ ៧៤៨តោន (+0,៧%) លើសបរិមាណនាំចេញរយៈពេល១២ខែឆ្នាំ២០១៥ ដែលមានចំនួន ៥៣៨ ៣៩៦តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែធ្នូនេះ មានចំនួន ៦២ ៤៥៥តោន ដែលមានការថយចុះចំនួន ១៩ ០២៤តោន (-៣០,៥០%) តិចជាងខែធ្នូ ឆ្នាំ២០១៥ និងបាននាំចេញទៅគាន់ទិសដៅចំនួន ៦៥ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (១២៧ ៤៦០តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៧៨ ៣២៩តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៦៤ ០៣៥តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (៣៨ ៨៧៧តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (២៨ ៦៩០តោន) ប្រទេសបែលហ្សិកឈរលំដាប់ទី៦ (២២ ៨៨៥តោន) ប្រទេសឆេកឈរលំដាប់ទី៧ (២២ ៨១៥តោន) ប្រទេសអ៊ីតាលី ឈរលំដាប់ទី៨ (១៨ ៦១៩តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៩ (១៧ ៦៧៣តោន) និងប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី១០ (១៦ ៦១៦តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៨៥ក្រុមហ៊ុន (កើនចំនួន ០៥ក្រុមហ៊ុនក្នុងខែធ្នូ)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានប្រចាំឆ្នាំនេះ (តោន) | បញ្ចេញលក់ប្រចាំឆ្នាំនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ៧១១ | ៥៤៥ |
| សរុប I | | ៥៨៣ | ៧៧៦ | ៧១១ | ៥៤៥ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១ ៩៥៧ | ១៥ ៣៨២ | ១៤ ៩១៩ | ១៦ ០៤៦ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៧៩ | ២ ៤៩៨ | ៨៩ | ១២០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ១ ១៦៩ | ១ ១៥៦ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៤ | ៣ ៨៩២ | ៣ ៨៣៣ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ៣ ០០៣ | ៣ ០៩៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វូរីសសស់ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ១ ៨៥៩ | ១ ៥០៣ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង អាស៊ាហែក) | ១ ៨៨២ | ៣ ៣៩០ | ៩៣៣ | ៩០១ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ១ ៧៩៤ | ១ ៧២៨ |
| ៩ | ក្រុមហ៊ុនគ្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ៤ ១០១ | ៤ ៥៩៣ |
| សរុប II | | ៣១ ១២២ | ៥៣ ៦៨៦ | ៣១ ៧៥៩ | ៣២ ៩៧៦ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៨ ៩៦០ | ២២២ ១៣៧ | ៧ ១២៩ | ៦ ៩៩៦ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៨៦ ៣៣១ | ១៥៤ ៤៥៤ | ៨៨ ២៥៣ | ៨៧ ៤៩៤ |
| សរុប III | | ៩៥ ២៩១ | ៣៧៦ ៥៩១ | ៩៥ ៣៨២ | ៩៤ ៤៩០ |
| សរុប I+II+III | | ១២៦ ៩៩៦ | ៤៣១ ០៥៣ | ១២៧ ៨៥២ | ១២៨ ០១១ |

• គួរកត់សម្គាល់ថា សម្រាប់ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូមានការធ្លាក់ចុះរហូតដល់ ១ ០៤២ដុល្លារក្នុងមួយតោន។ មកទល់ពេលនេះតម្លៃកៅស៊ូបានកើនឡើងវិញក្នុងរង្វង់ ១ ៧០៣ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានបើកវគ្គបណ្តុះបណ្តាលដល់កសិករចំនួន ០៦វគ្គគឺៈ (១).វគ្គដាំដុះនិងថែទាំកៅស៊ូ (២).ការគ្រប់គ្រងច្បារពូជនិងថ្នាលកូន (៣).ការប្រមូលផលទឹកជ័រនិងការចៀរជ័រ (៤).ការគ្រប់គ្រងសមាសភាពចង្រៃនិងជំងឺ (៥).ការកែច្នៃកៅស៊ូសន្លឹកនិងចំណាត់ថ្នាក់ (៦).អត្តសញ្ញាណកម្មក្លូនកៅស៊ូ

- ថ្នាក់ដឹកនាំមន្ត្រីជំនាញចំនួន ១៣នាក់បានចូលរួមកិច្ចប្រជុំនិងសិក្ខាសាលានៅប្រទេសថៃ ម៉ាឡេស៊ី ស្រីលង្កា និងសាធារណរដ្ឋប្រជាមានិតចិន

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)

- រៀបចំផ្ញើក្លូនកៅស៊ូទៅប្រទេសថៃចំនួន ០៥ក្លូនៈ FDR 4575, CDC 312, FDR 5665, FRD 5788 និង PMB1 សរុបចំនួន ១៥ម៉ែត្រ

- បានទទួលក្លូនកៅស៊ូពីប្រទេសហ្គាណាចំនួន ០៣ក្លូនៈ FDR 5802, FDR 5597 និង FDR 5240 ហើយរៀបចម្ការបំបៅសរុបចំនួន ៥៦ដើម

- បានធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិបាន០៣លើកជាមួយ IRA (International Rubber Association) ដើម្បីការទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSR (Technically Specified Rubber)

- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ៣២០ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យ BoA (Bureau of Accreditation) គុណភាពរបស់រោងចក្រកែច្នៃកៅស៊ូ

- ចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ CSR និងទទួលស្គាល់ជាផ្លូវការមន្ទីរពិសោធន៍យថាប្រភេទក្រុមហ៊ុន ស៊ីធី រ៉ាប់ប៊ើរ នៅខេត្តត្បូងឃ្មុំ

- បានចូលរួមជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya (ប្រទេសជប៉ុន) និងពីសាកលវិទ្យាល័យ Hawaii (USA) ដើម្បីជួសជុលនិងថែទាំឧបករណ៍ Flux Tower និងSap Flow

- ចូលរួមការងារជាមួយជំនាញការអង្គការ UNIDO (United Nations Industrial Development Orgarnization) ដើម្បីរៀបចំសៀវភៅសម្រាប់ការទទួលស្គាល់ការធ្វើតេស្ត និងការបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍

- បានដាំដុះកៅស៊ូឆ្នាំ២០១៦ ចំនួន ១៩ហ.ត

- បានបង្កើតចម្ការពិសោធន៍ថ្មីចំនួន ០១នៅចម្ការកៅស៊ូក្រែក

- បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទកៅស៊ូអន្តរជាតិនៅខេត្តសៀមរាបដែលមានប្រទេសជាសមាជិកចូលរួមចំនួន ១៨ប្រទេស និងសមាសភាពពាក់ព័ន្ធចូលរួមប្រមាណជាង ៣០០នាក់។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បើកវេទិកាប្រជុំចរចាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងកសិករ (ភាគីអ្នកផលិត) និងក្រុមហ៊ុន (ភាគីអ្នកទិញ) នៅក្នុងខេត្តបាត់ដំបងបានចំនួន០១លើក ស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅនឹងទីផ្សារតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលមានការចូលរួមពីអាជីវករ និងកសិករមកពីសហគមន៍កសិកម្ម

- បានចូលរួមប្រជុំជាមួយក្រុមហ៊ុនជប៉ុន JAPAN FARM PRODUCTS (Cambodia) Co., Ltd និង SARAYA (Cambodia) Co., Ltd ស្តីពីគម្រោងទាក់ទងវិស័យកសិកម្មក្រោមជំនួយរបស់ ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ JICA

- បានចូលរួមប្រជុំស្តីអំពីការរៀបចំអនុស្សរណៈនៃការយោគយល់គ្នានិងផែនការសកម្មភាពរវាងភាគីកម្ពុជា និងភាគីថៃ

- បានបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងសេចក្តីព្រាងស្នើសុំចុះកិច្ចសន្យា គំរូកិច្ចសន្យា សារាចរណែនាំ និងរៀបចំការបង្កើតគណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានរៀបចំផែនការសកម្មភាពគម្រោងលើកទី៣ ដាក់ជូនសហភាពអឺរ៉ុប (EU) ពាក់ព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានរៀបចំប្រគល់ទទួលអគារមន្ទីរពិសោធន៍កសិកម្មកម្ពុជា សម្ភារការិយាល័យដែលមានទីតាំងនៅសាលាជាតិកសិកម្មព្រែកលៀបដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

- បានរៀបចំ និងបញ្ជូនសំណើគម្រោងទៅភាគីចិន ស្តីពីការកសាងសមត្ថភាពលើការត្រួតពិនិត្យគុណភាព សុវត្ថិភាពនៃផលិតផលកសិកម្ម និងចំណីអាហារ ដើម្បីបណ្តុះបណ្តាលថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៧ និងគម្រោងគាំទ្រសកម្មភាពរបស់មន្ទីរពិសោធន៍កសិកម្មកម្ពុជាលើគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ

- បាននិងកំពុងសិក្សាស្វែងយល់អំពីសារធាតុគីមីដែលត្រូវយកទៅប្រើប្រាស់ និងរៀបចំដំឡើងឧបករណ៍ក្នុងមន្ទីរពិសោធន៍

- ចុះពិនិត្យ និងវាយតម្លៃស្ថានភាពនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលអនុវត្តដោយក្រុមហ៊ុន CP (ចិញ្ចឹមមាន់ និងជ្រូក) សហគមន៍ស្វាយក្នោក សហគមន៍ស្វាយនៅខេត្តកំពង់ស្ពឺ ក្រុមហ៊ុនអាកាស្យាខេត្តព្រះសីហនុ និងសហគមន៍ម្រេចខេត្តកំពត

- បន្តសហការជាមួយអ្នកជំនាញការកូរ៉េមកពី KOICA ដែលកំពុងបំពេញបេសកកម្មនៅនាយកដ្ឋានកសិ-ឧស្សាហកម្មក្នុងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

## ៤ ផ្នែកផលិតកម្ម និងបសុពេទ្យបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជា

លក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ

- **ការងារកែលម្អពូជៈ** មន្ត្រីជំនាញបានបន្តចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព មានការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយដៃគូពាក់ព័ន្ធ។
- **ការងារឡជីវឧស្ម័នៈ** បន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននិងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមានៈ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន ១ ៣២២ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន ២៥០ឡ។
- **ចំណីសត្វៈ** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វៈ** បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសូនដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

### ៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វៈ** ក្នុងឆ្នាំ២០១៦នេះ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៤៥ ៤០២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានចំនួន ៤២ករណី និងបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៨២៨គីឡូក្រាម និងដាក់ពិន័យជាទឹកប្រាក់ចំនួន ៤៧លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។
- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៤៨កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។
- **ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន ១៤៨កន្លែង** ហើយចំនួនសត្វដែលបានពិឃាតក្នុងសត្តឃាតដ្ឋានទាំងនោះ ដូចមានតារាងខាងក្រោមៈ

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១២ | | | | | |
| ២ | កណ្តាល | ២៣ | | ៥ ២៦៣ | | ៤៦ ៩០៤ | ៧៥៨ ៧២៤ |
| ៣ | កំពង់ស្ពឺ | ១១ | | ៧ ៧២៦ | | ៣៤ ៥២៤ | |
| ៤ | ព្រៃវែង | ១២ | | ៣១៩ | | ២ | ២ ៩៩៨ |
| ៥ | ស្វាយរៀង | ៨ | | | | | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ៦ | | ២ ៩៤១ | | ១៧៧ | ២២ ៧០៦ |
| ៨ | បាត់ដំបង | ១៤ | | ១៥ ២៥៥ | ២៩៨ | ៦៥ ៣០៨ | |
| ៩ | បន្ទាយមានជ័យ | ១១ | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | ៧ ៤០៥ | ៨០២ | ៣៥ ៨០៧ | |
| ១២ | ព្រះសីហនុ | ៣ | | ៩២៨ | ៥០ | ១០ ០៩៩ | ១៥៦ ១៣៦ |
| ១៣ | កែប | ១ | | ១៦៨ | | ៣ ១៧០ | |
| ១៤ | កំពត | ៥ | | ៣ ០៧៩ | ៥ | ២៥ ៧៨៥ | ១៤ ១២០ |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | | | | |
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | ១៤៧ | | ៩៣ | ១ ០១៥ |
| ១៩ | មណ្ឌលគិរី | ២ | | | | | |
| ២០ | ប៉ៃលិន | ៣ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | | | | |
| ២២ | តាកែវ | ១ | ១៨ | ៥ ០៦៨ | | ៣៧ ៨៥៤ | |
| ២៣ | កំពង់ចាម | ០ | ១០ | ៦ ៩៩៣ | | ៤០ ០៥៨ | ៣៨ ៧៥៥ |
| ២៤ | ត្បូងឃ្មុំ | ០ | ៧ | | | | |
| ២៥ | ព្រះវិហារ | ០ | ៦ | | | | |
| សរុប | | ១៤៨ | ៤១ | ៥៥ ២៩២ | ១ ១៥៥ | ២៩៩ ៧៨១ | ៩៩៤ ៤៥៤ |

• **ការងារនីតិកម្មនិងវិវាទ៖** បន្ទាប់ពីច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្រសួងបានរៀបចំបោះពុម្ពនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់តាមអាទិភាព។ គួរកត់សម្គាល់ថា នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វតាមរយៈអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។

**៤.៣ ការងារស្រាវជ្រាវ៖**

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ក្នុងឆ្នាំ២០១៦នេះ អង្គភាពជំនាញបានពិនិត្យវត្ថុវិភាគសរុបចំនួន ៧ ៦២២ករណី។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំគាម៉ៅអានគោសរុបចំនួន ១១៤ក្បាល ក្នុងនោះគោបាចំនួន ១ក្បាល គោប្រាម៉ាន់កាត់ចំនួន ៦ក្បាល គោជំទង់ចំនួន ៣៨ក្បាល គោបៅដោះចំនួន ២៩ក្បាល គោកំដែងសែនចំនួន ៤០ក្បាល គោកើតថ្មីចំនួន ០៥ក្បាល គោងាប់ចំនួន ០៧ក្បាល និងគោលក់ចំនួន ៤៦ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុបចំនួន ៧១៨ក្បាល ក្នុងនោះជ្រូកបាចំនួន ៦ក្បាល ជ្រូកមេចំនួន ៧៩ក្បាល កូនជ្រូកចំនួន ៦៣៩ក្បាល មេជ្រូកត្រៀមលក់ចំនួន ១១ក្បាល ជ្រូកថែមថ្មីចំនួន ១២ក្បាល កូនជ្រូកត្រៀមលក់ចំនួន ១៤៦ក្បាល និងជ្រូកលក់ចំនួន ៥០០ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងដោយចៃដន្យ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានរៀបចំចុះកិច្ចព្រមព្រៀងព្រៃសហគមន៍សរុបចំនួន ០៩កន្លែង មានផ្ទៃដីសរុបទំហំ ២ ៥៨៨ហ.ត ក្នុងនោះស្ថិតនៅក្នុងខេត្តបាត់ដំបងចំនួន ០៦កន្លែងមានផ្ទៃដីសរុបទំហំ ៧៨៦ហ.ត ខេត្តព្រះវិហារចំនួន ០៣កន្លែង មានផ្ទៃដីទំហំ ១ ៨០២ហ.ត

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តនិងយានយន្តជូនក្រុមហ៊ុន និងអតិថិជនសរុបចំនួន ៨៤គ្រឿង ក្នុងនោះ ជូនប្រជាជនចំនួន ២៨គ្រឿង និងក្រុមហ៊ុនចំនួន ៥៦គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២៣ និងអតិថិជន ១៥នាក់ រួមមានឈើហ៊ុបមូលចំនួន ៥៦ ៤៧៤ម៣ ឈើអារចំនួន ១ ៤៣១ម៣ ឈើជ្រុងចំនួន ៤ ៥៥៨ម៣ កូនក្រឡឹងចំនួន ៤០១ម៣ កូនឈើចំនួន ៥៧៨ ៨៣៥ដើម អុសចម្រុះចំនួន ១៤៩ ៨២៤ស្ទេរ ជ័រទឹកចំនួន ១ ៣២០តោន ជ័រចុងចំនួន ១០តោន ពកបេងចំនួន ៥៥៨គីឡូក្រាម ឬស្សីព្រៃចំនួន ៦៤២តោន ៣១៣ និងផ្តៅចំនួន ៤តោន៦១២

- បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន៦ក្រុមហ៊ុន គឺក្រុមហ៊ុន GREEN ISLAND AGRI-CULTURAL DEVELOPMENT(CAMBODIA) Co.,LTD នៅខេត្តក្រចេះ ក្រុមហ៊ុនសិលាជាម៉ិច ក្រុមហ៊ុនសំអឿនសុវណ្ណ ក្រុមហ៊ុនអាយរ៉ុនវូដអ៊ីន ក្រុមហ៊ុនហេងណុង ក្រុមហ៊ុនហេងរួយ នៅខេត្តព្រះវិហារ ក្រុមហ៊ុនអេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី នៅខេត្តរតនគិរី និងក្រុមហ៊ុន វ័ត្តសម្បត្តិ នៅខេត្តបាត់ដំបង។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានចុះប្រមូលសំណាកសត្វកណ្តុរចំនួន ៣ ៤៣៣សំណាក ស្មើនឹង ៣២១ក្បាល ដើម្បីធ្វើការវិភាគរកមេរោគ និងជំងឺនៅខេត្តមណ្ឌលគិរី កំពង់ធំ និងខេត្តព្រះវិហារ

- បានចុះប្រមូលសំណាកសរុបចំនួន១ ៣៦៧សំណាក ពីសត្វប្រចៀវ-ជ្រឹងចំនួន ៤៨៦ក្បាល ដើម្បីយកទៅធ្វើការវិភាគរកមេរោគដែលមាននៅក្នុងខ្លួនសត្វប្រចៀវ-ជ្រឹងនៅខេត្តកណ្តាល បាត់ដំបង និងខេត្តកំពត

- បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋចំនួន ៥០គ្រួសារ ដែលទទួលរងការបំផ្លាញដំណាំពីសត្វដំរីព្រៃ នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ

- បានផ្តល់ជូនឧបករណ៍ និងសម្ភារសម្រាប់បង្អើលដំរី ដល់ប្រជាពលរដ្ឋនៅភូមិព្រែកស្វាច់ ឃុំកោះស្តេច ស្រុកគីរីសាគរ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ដែលមានគ្រួសារសរុបចំនួន ៦គ្រួសារ រួមមានកាំជ្រួច ២០០ដើម ភ្លើងញាក់ចំនួន ១០គ្រឿង ខ្សែក្រណាត់បន្ទះ និងប្រេងខ្មៅបង្ការពេលដំរីចូលមកបំផ្លាញ

- បានចុះប្រមូលសំណាកលាមកដំរីស្រស់នៅតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុងចំនួន ០៥លើកដោយទទួលបានសំណាកលាមកដំរីសរុបចំនួន ៣៧១សំណាក ក្នុងនោះលាមកស្រស់មានចំនួន ២០៦សំណាក លាមកស្រស់បង្គួរមានចំនួន ១៣០សំណាក និងលាមកមិនស្រស់ (លើសពីប្រាំថ្ងៃ) មានចំនួន ៣៥សំណាក

- ក្រុមហ៊ុនចំនួន ៦បានគ្រប់គ្រងកសិដ្ឋានចំនួន ៧ដែលមានស្វាក្តាមសរុបចំនួន ៥៥ ៣៧៤ក្បាល និងនាំចេញចំនួន ៦ ៧៥០ក្បាល។

### ៥.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន ១ ៧៦៦ក្បាល សត្វកើតថ្មីចំនួន ៧៨ក្បាល ព្យាបាលសត្វព្រៃរបួស និងឈឺចំនួន ១ ០៧១ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន ១ ៥៣៧ក្បាល ជួសជុលផ្លូវមានប្រវែង ២៨គីឡូម៉ែត្រ កាប់ឆ្ការអនាម័យព្រៃចំនួន ៤៧ហ.ត សាងសង់និងជួសជុលទ្រុងសត្វឬសំណាង់ផ្សេងៗបាន ៩ ១៦៧ម២។ សរុបរួមសម្រាប់ឆ្នាំ២០១៦ សត្វព្រៃសរុបចំនួន ១ ៣២០ក្បាល (បក្សី៥០ប្រភេទ ថនិកសត្វ៤៥ប្រភេទ និង ល្មូន១៣ប្រភេទ)។

### ៥.៤ ការងារដាំដើមឈើ

- បានបញ្ចប់ការដាំកូនឈើជាចម្ការថ្មីនៅលើផ្ទៃដីទំហំ ១៥០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ អូរបឹងរូង ខេត្តកំពង់ធំ

- បានបញ្ចប់ការដាំកូនឈើជាចម្ការនៅលើផ្ទៃដីទំហំ ១៥០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាល ត្បាលឆាយ ខេត្តព្រះសីហនុ

- បានបញ្ចប់ការដាំកូនឈើជាចម្ការនៅលើផ្ទៃដីទំហំ ៥០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើយុនរាម ខេត្តសៀមរាប

- បានថែទាំចម្ការឈើចាស់ពីឆ្នាំទី១ ដល់ឆ្នាំទី៥ លើផ្ទៃដីសរុបទំហំ ២ ១៩៣ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទូទាំងប្រទេស ដោយបាននិងកំពុងពង្រឹងការយាមល្បាត ដើម្បីទប់ស្កាត់ការកាប់ រុករានទន្ទ្រាន ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ និងទប់ស្កាត់ភ្លើងព្រៃ

- បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ១ ៦៥៦ ៧៦៤ ដើម

- ចែកកូនឈើជូនប្រជាពលរដ្ឋបានចំនួន ១ ៥០៨ ៧៥១ដើម

- បានរៀបចំពិធីរុក្ខទិវាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ តំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។**

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេសលើក្រុមហ៊ុនចំនួន ១៥ និងក្រុមហ៊ុនចំនួន ២៧ បានស្នើសុំបន្តសុពលភាព

- ចុះសិក្សាអត្រាកែច្នៃឈើនៅរោងម៉ាស៊ីនអារ កែច្នៃឈើជូនក្រុមហ៊ុនចំនួន ០៤

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាទៅបរទេសចំនួន ០៤ក្រុមហ៊ុន ដែលមានបរិមាណសរុប ៣ ០២៣ម៣ និងជ័រទឹកចំនួន ១៦០តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ០៤ក្រុមហ៊ុន ប្រភេទឈើ Chanfuta Taly Wood Umbila និងឈើ MDF មានបរិមាណសរុប ៩៨៨ម៣។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ១៧ ១៩៩ ៣៨០ ០០៥រៀល និងចំណូលពីសេវាសាធារណៈចំនួន ៥ ៥៨០ ៨២០ ២៨៧រៀល និង ១៤០ ៥០៤,៦៦ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១ ៤៩០ករណី ដោយបញ្ជូនទៅតុលាការចំនួន ១ ១១០ករណីនិងពិន័យអន្តរការណ៍ចំនួន ៣៨០ករណី

- ឃាត់ខ្លួនជនល្មើសចំនួន ២៣នាក់ និងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ៧ ១៥៣ម៣ ឈើអារចំនួន ៦ ២៧២ម៣ ឈើគ្រាក់ក្រញូងចំនួន ៥៨ម៣ និង១ ៨១៤គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ១ ៨១៤ក្បាល និង៣ ៣២៤គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត ដកហូតរណារយន្តបានចំនួន ២៩៥គ្រឿង និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ២០៨ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ៥ ២១៣ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន ៣៥លើក នៅខេត្តកំពង់ចាមចំនួន ០១លើក ត្បូងឃ្មុំចំនួន ០២លើក ក្រចេះចំនួន ០៨លើក ស្ទឹងត្រែងចំនួន ០៤លើក មណ្ឌលគិរីចំនួន ០៤លើក រតនគិរីចំនួន ០៦លើក កំពង់ធំចំនួន ០២លើក ព្រះវិហារចំនួន ០២លើក កំពង់ស្ពឺចំនួន ០១លើក កាកែវចំនួន ០១លើក តំពតចំនួន ០១លើក កំពង់ឆ្នាំងចំនួន ០១លើក ពោធិ៍សាត់ចំនួន ០១លើក និងខេត្តបាត់ដំបងចំនួន ០១លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- បានចូលរួមយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើតាមស្មារតីនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

៦.១.១ នេសាទទឹកសាប

- ដាយត្រី អនុវត្តបានចំនួន ១៣ ៩៥០តោន ស្មើនឹង ១១៦,២៥% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៥២៤តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ៣៤៨ ៦០០តោន ស្មើនឹង ១០១,៣៤% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៩ ៣៣១តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ១៤៦ ៣០០តោន ស្មើនឹង ១០១,៦០% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១១ ០៩០តោន។

៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១២០ ៦០០តោន ស្មើនឹង ១០៩,៦៤% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១០០តោន។

### ៦.២ វារីវប្បកម្ម

- បានប្រារព្ធមច្ឆទិវាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ១៧៤ ៥៥០តោន ស្មើនឹង ១០១,០១% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៣១ ៤០៩តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ៣០៧ ០០០ក្បាល ស្មើនឹង១២២,៨០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៨ ៣៣១ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួន ១៩៤ ០០០ ០០០កូន ស្មើនឹង ១០៧,៧៨% នៃផែនការ ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥កើនឡើងចំនួនប្រមាណ ១៣ ៥០០ ០០០កូន

- បានចេញប្រកាសលេខ៣២៥ប្រក.កសក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការចិញ្ចឹមត្រីរស់ និងត្រីឆ្តោរ។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាប អនុវត្តបានចំនួន ៧០ ២០០តោន ស្មើនឹង ៨៥,៦១% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១៩ ៦០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន ១០ ៥២៥តោន ស្មើនឹង១៣១,៥៦% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៤២៥តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន ៥៥ ០០០ ០០០លីត្រ ស្មើនឹង ១១០,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២ ០០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៩ ១០០តោន ស្មើនឹង ៦០,៦៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១ ៤០០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៥ ២០០តោន ស្មើនឹង ១០៤,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៣០០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៣ ៦៥០ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣ ៤៧៤ករណី និងសមុទ្រចំនួន ១៧៦ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ១ ២៩៤ ១៧៨ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ២៤ ០០៧មាត់ បង្គោល/ចម្រឹងចំនួន ៦០៧ ៩១៦ដើម ឧបករណ៍នេសាទត្រីចំនួន ៣៨៨គ្រឿង សម្រាស់ទំហំ ៧៧ ១២៤ម៉ែត្រក្រឡា របាំងព្រួលប្រវែង ១៥ ៤៩៥ម៉ែត្រ និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ១១៣ ៦៦៣គ.ក្រ

- ចាប់ពីដើមឆ្នាំ២០១៦នេះ បានផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ១៦៩វគ្គ ដោយមានអ្នកចូលរួមចំនួន ៦ ២៩៩នាក់ ក្នុងនោះស្ត្រីចំនួន ៩៨៦នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត។ ជាពិសេសការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប។

### ៦.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផលសម្រាប់ឆ្នាំ២០១៦ ចំនួន ២ ២៨៦ ៩៣៥ ២៧៩រៀល ស្មើនឹង ៧៦,២៣% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១ ៨៨៧ ៦០២ ៤៧៨រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទដែលរួមមានស្រូវចំនួន ៦ ៧៣៥បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទសរុបចំនួន ១ ៥៦៩បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៨ ៣០៤បញ្ជីក/សំណាក។ ធ្វើយុវកម្មស្រូវចំនួន ២ ៣២៩បញ្ជីក/សំណាក បានវាយតម្លៃ និងកំណត់លក្ខណៈសំណាកម្ទេសនិងក្រសក់ស្រូវបានចំនួន ៤៩សំណាក និងបានចុះប្រមូលបន្ថែមសំណាកដំណាំបានចំនួន ២២ប្រភេទ សរុបទាំងអស់មានចំនួន ៥០៤សំណាក ពីខេត្តចំនួន ៥ គឺខេត្តកំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ

- បានបញ្ចេញពូជស្រូវខា១៦ ជាពូជស្រូវស្រាលមិនប្រកាន់រដូវធន់នឹងកម្ដៅខ្ពស់ សមស្របដាំដុះក្នុងដើមរដូវវស្សានិងរដូវប្រាំង និងពូជស្រូវស្មាច់០២ ជាពូជស្រូវធ្ងន់ប្រកាន់រដូវសមស្របសម្រាប់ស្រែជម្រៅនៃស្រែទំនាបរំពឹងទឹកភ្លៀង និងមានអង្ករក្រហម

- ពិសោធន៍ស្រាវជ្រាវអំពីការហូរច្រោះដីដោយដំណាំដំឡូងមី (លទ្ធផលសរុបរយៈពេល២ឆ្នាំៈ ២០១៥ និង ២០១៦)

- ពិសោធន៍ស្រាវជ្រាវអំពីសំណើមដីទៅលើដំណុះនៃដំណាំសណ្តែកដី សណ្តែកបាយ ពោត និងស្រូវបន្ទាប់ពីប្រមូលផលស្រូវវស្សា នៅលើក្រុមដីប្រទះឡាង ដែលមានសមត្ថភាពរក្សាទឹកទាប

- ពិសោធន៍ស្រាវជ្រាវអំពីការបំបែកស្រទាប់បាតនង្គ័លរបស់ក្រុមដីប្រទះឡាងបន្ទាប់ពីប្រមូលផលស្រូវវស្សាលើដំណាំពោត និងសណ្តែកដី

- បានអនុវត្តក្នុងរយៈពេល៩ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៦ បានបង្ហាញយ៉ាងច្បាស់ថា៖ (១). ការជំនួសពូជស្រូវកសិករដោយពូជស្រូវថ្មីៗ រួមមានពូជស្រូវពូជផ្ការំដួល ផ្ការមៀត ផ្ការំដេង សែនពិដោរ និងជលសារ បានបង្កើនទិន្នផលពី២,៤៩តោន/ហ.ត ទៅ៣,០៧តោន/ហ.ត និងទទួលបានប្រាក់ចំណេញដុល ០,៦២លានរៀល ខ្ពស់ជាងការប្រើប្រាស់ពូជកសិករ (១.២៦លានរៀល) និង(២). ការអនុវត្តតាមបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវបានបង្កើនទិន្នផលស្រូវរហូតដល់៣,៨៩តោន/ហ.ត និងទទួលបានប្រាក់ចំណេញដុលខ្ពស់រហូតដល់២,៥១លានរៀលក្នុងមួយហិកតា

- បានចុះសិក្សាក្នុងស្រែចំនួន ៦៤ នៅខេត្តតាកែវ កំពង់ធំ បាត់ដំបង និងព្រៃវែងនៅបីដំណាក់កាលបានបង្ហាញជារួមថា ស្រូវក្រូវបានបំផ្លាញដោយ កណ្តុរ៥,២% ខ្ទុងស៊ីជាលិកាស្លឹកស្រូវ៥,៣% ស្រូវមានជំងឺរលាកគែមស្លឹកដោយបាក់តេរី២,៨% អុចត្នោត៦,៨% ឆ្នូតត្នោត១១,៦% ខ្វារអំបោះស្លឹក០,២% និងខ្វារអំបោះកគួរ០,៧%

- បានចុះសិក្សាដើម្បីកំណត់រកសមាសភាពសត្វល្អិតចង្រៃសំខាន់ៗបំផ្លាញដំណាំស្វាយនាដំណាក់កាលផ្សេងៗក្នុងខេត្តកំពង់ចាម កំពង់ស្ពឺ កណ្ដាល សៀមរាប និងបាត់ដំបងបានបង្ហាញថា ដង្កូវចោះផ្លែ និងរុយផ្លែ មានវត្តមានច្រើនជាងគេចាប់ពីដំណាក់កាលចេញផ្លែរហូតដល់ទុំ។ ចំណែកជំងឺវិញមាន Anthracnose, leaf spot និង fruit rot

- បានធ្វើការផ្សព្វផ្សាយបច្ចេកទេសស្រែបង្ហាញនិងបណ្តុះបណ្តាលកសិករចំនួន ៦៨លើក នៅខេត្តចំនួន ១២ ដែលមានកសិករចូលរួមសរុបចំនួន ១ ៩៩០នាក់ ព្រមទាំងបានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន ៣៤០គ្រួសារដោយក្នុងមួយគ្រួសារបានចំនួន ៥គ.ក្រ មានសរុបចំនួន ១ ៧០០គ.ក្រ ហើយដែលកសិករទាំងនោះផលិតជាគ្រាប់ពូជបានចំនួនប្រមាណ ៨០តោន ទុកសម្រាប់ប្រើប្រាស់ក្នុងឆ្នាំក្រោយ

- គេហទំព័រ http://www.cardi.org.kh និង http://crkb.org.kh: ក្នុងរយៈពេលមួយឆ្នាំ២០១៦ នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៦៨៦ ១៥៣នាក់ ហើយគិតជាមធ្យមមានប្រមាណ ២ ០៧៩នាក់/ថ្ងៃ កើនលើសមធ្យមប្រចាំឆ្នាំ២០១៥ ចំនួន ៨៧៦នាក់/ថ្ងៃ។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ២២៥ក្រុមហ៊ុន សរុបចំនួន ២ ៨៣៥មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ២០៦ក្រុមហ៊ុន ត្រូវជា២៩១ករណី
- ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មចំនួន ១៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតចុះបញ្ជិកាមានចំនួន ២២៥ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ០៦ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ១០៦ក្រុមហ៊ុន សរុបចំនួន ៦៤៤សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តដែលមានសមាសភាពចូលរួមសរុបចំនួន ៧៦៦នាក់

- បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត បើកវគ្គអប់រំវិជ្ជាជីវៈនិងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវករជាអ្នកលក់ដុំ លក់រាយសម្ភារកសិកម្មដែលមានសមាសភាពចូលរួមចំនួន ៣២៧នាក់

- បានសហការជាមួយ GIZ ដើម្បីរៀបចំសិក្ខាសាលាស្តីពីបទដ្ឋានគតិយុត្តក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រក្នុងវិស័យកសិកម្មដែលមានសមាសភាពចូលរួមចំនួន ៩៩នាក់

- បានរៀបចំសិក្ខាសាលាស្តីពី ការណែនាំអំពីនីតិវិធីក្នុងការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មដែលមានសមាសភាពចូលរួមចំនួន ១៤១នាក់។

### ៨.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្មចំនួន ៧៨ក្រុមហ៊ុន

- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៩៩ ១០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ១៤ អាជីវករលក់ដុំ និងលក់រាយចំនួន ២៧ដេប៉ូ

- វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្គត់ផ្គង់ចែកចាយចំនួន ០៥ក្រុមហ៊ុន ដកហូតវិញ្ញាបនបត្របញ្ជាក់បញ្ជិកាចំនួន ០៦ក្រុមហ៊ុន ចេញលិខិតព្រមានចំនួន ០៥ក្រុមហ៊ុន។

## ៩ ផ្នែករដ្ឋបាល

- ក្នុងឆ្នាំ២០១៦នេះ ទទួលលិខិតពីក្រសួង-ស្ថាប័ននានា បានចំនួន ៤ ១១៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៤ ២៥៥ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ៥២១ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១១ ៣៣៦ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៧៦៦ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ៣៥០ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អប្រសើរ។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៩០៨នាក់ ក្នុងនោះនារីចំនួន ១ ៥២០នាក់ ស្មើនឹង ២២% រួមមាន៖

+ អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៨៥នាក់ ក្នុងនោះនារីចំនួន ៧៧១នាក់ ស្មើនឹង ២៧%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ៤ ១២៣នាក់ ក្នុងនោះនារីចំនួន ៧៤៩នាក់ ស្មើនឹង ១៨% (បានបញ្ចូលមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តរួចហើយ)

- ចេញប្រកាសតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចជូនមន្ត្រីរាជការសរុបមានចំនួន ២៩៧នាក់ (នារីចំនួន ៣៦នាក់) ក្នុងនោះ៖ អង្គភាពថ្នាក់កណ្តាលចំនួន ២៤៩នាក់ (នារីចំនួន ៣៣នាក់) និងអង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៤៨នាក់ (នារីចំនួន ០៣នាក់)

- ចេញប្រកាសលុបឈ្មោះមន្ត្រីទទួលមរណភាពចេញពីក្របខ័ណ្ឌមានចំនួន ៥២នាក់ ក្នុងនោះបោះបង់ការងារមានចំនួន១២នាក់ សុំលាឈប់ពីការងារចំនួន ១២នាក់ និងមរណភាពចំនួន ២៨នាក់

- ចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងចំនួន ៨៥នាក់ ក្នុងនោះ ផ្ទេរចេញចំនួន ៦៨នាក់ និងផ្ទេរចូលចំនួន ១៧នាក់ ផ្ទេរចេញ ចូលផ្ទៃក្នុងក្រសួងចំនួន ១២០នាក់

- បានចុះពិនិត្យ និងវាយតម្លៃការគ្រប់គ្រងមន្ត្រីកសិកម្មរាជធានី-ខេត្ត លើ០៣តំបន់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារមានចំនួន ១០៩នាក់ ក្នុងនោះ ប្រចាំឆ្នាំចំនួន ៧៤នាក់ ច្បាប់ព្យាបាលជំងឺចំនួន ០៨នាក់ និងច្បាប់សម្រាកលំហែមាតុភាពចំនួន ២៧នាក់

- បានធ្វើប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីកសិកម្ម អង្គភាពថ្នាក់កណ្តាល និងរាជធានី-ខេត្ត

- ចេញប្រកាសឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ២៣៧នាក់

- ចេញប្រកាសឱ្យមន្ត្រីរាជការចូលបម្រើការងារក្នុងអង្គភាពដើមវិញមានចំនួន ១០៨នាក់

- ចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ១៣៩នាក់

- ចេញប្រកាសស្តីពីការអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាមានចំនួន ១ ០២៤នាក់

- បានធ្វើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន ៣ ១០៣

- ការងារបណ្តុះបណ្តាលមន្ត្រីរាជការក្នុងនិងក្រៅប្រទេសសរុបចំនួន ៣ ១៧៦នាក់ (នារីចំនួន៨៤៤)

- បានប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៦ ចំនួន ៣៣៨នាក់។

ចំណុចគួរកត់សម្គាល់មួយទៀត គឺគ្រឹះស្ថានឧត្តមសិក្សាទាំង០៣ បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីផ្សព្វផ្សាយ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនដែលមាននិស្សិត មន្ត្រីរាជការចូលរួមសរុបទាំងអស់ចំនួន ១ ៨១៩នាក់។ អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសគ្រឹះស្ថានឧត្តមសិក្សាទាំង៣ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង កំពង់ចាម) បានធ្វើការផ្សព្វផ្សាយនិងចាត់វិធានការទប់ស្កាត់សកម្មភាពប៉ុនប៉ងនាំឱ្យមានភាពវឹកវរក្នុងសង្គម ពិសេសចលនាស្លៀកពាក់ខ្មៅដោយមានមន្ត្រីរាជការ និងនិស្សិតចូលរួមប្រមាណ៥ ០០០នាក់។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ានដើម្បីរៀបចំសិក្ខាសាលាថ្នាក់តំបន់នៃក្រុមការងារជំនាញបច្ចេកទេសអាស៊ាន ក្នុងការរៀបចំគោលនយោបាយព្រៃឈើអន្តរជាតិ កិច្ចប្រជុំលើកទី១២ នៃក្រុមការងារបច្ចេកទេស

អាស៊ាន កិច្ចប្រជុំលើកទី៤ នៃក្រុមប្រឹក្សាស្បៀងបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូក៣ ដែលមានសមាជិកចូលរួមមកពីបណ្តាប្រទេសអាស៊ានទាំង១០

- សហការជាមួយអង្គការ GROW ASIA ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីភាពជាដៃគូរបស់កម្ពុជា ដើម្បីអភិវឌ្ឍន៍កសិកម្មឱ្យមាននិរន្តរភាព

- បានសម្របសម្រួលជាមួយ CDC លើសំណើបញ្ជូនគម្រោង Improvement of Commune Level Agriculture Extension System Rural Development ទៅសាធារណរដ្ឋកូរ៉េ

- ធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីស្នើសុំសិទ្ធិប្រទានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូល

- បានសម្របសម្រួលទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីផ្តល់គម្រោងផែនការវគ្គ ២០១៦-២០១៨ សម្រាប់អនុវត្តផែនការសកម្មភាពមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រក្រុងតូក្យូថ្មី២០១៥ ការផ្តល់យោបល់លើសេចក្តីព្រាង Roadmap for Asia Cooperation Dialogue (ACD) Regional Connectivity សម្រាប់លើកយកទៅអនុម័តនៅក្នុងកិច្ចប្រជុំកំពូល ADC លើកទី២ នៅទីក្រុងបាងកក ប្រទេសថៃ បន្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ VSO និងសេចក្តីព្រាងអនុស្សរណៈស្តីពីផលិតកម្មកសិកម្ម កម្ពុជា-រុស្ស៊ី

- បានសម្របសម្រួលទៅក្រសួងផែនការ សុំផ្តល់យោបល់លើសេចក្តីព្រាងស្តីពីការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម

- បានស្នើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាលដើម្បីសុំចុះហត្ថលេខាលើពិធីសាររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការនាំអង្ករ និងចុងអង្ករទៅប្រទេសចិន

- បានសម្របសម្រួលទៅក្រសួងពាណិជ្ជកម្ម អំពីការផ្តល់យោបល់លើសេចក្តីព្រាងឯកសារគោលគំនិត ស្តីពីការតភ្ជាប់អាស៊ាន-សហរដ្ឋអាមេរិក

- បានលើកសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសុំអ្នកជំនាញការស្ម័គ្រចិត្តកូរ៉េ World Friend Korea: Advisors Program ១រូប តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ សម្រាប់នាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

- បានសម្របសម្រួលរាល់កិច្ចការទំនាក់ទំនងក្នុង និងក្រៅប្រទេសដើម្បីជូនថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមបេសកកម្ម សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅក្រៅប្រទេស រួមទាំងការទទួលជួបសវនាការរបស់ថ្នាក់ដឹកនាំជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាផងដែរ

- បានរៀបចំទិវាវហោស្ថានកម្មនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ដែលមានសមាសភាពពាក់ព័ន្ធ និងកសិករចូលរួមជាង ៥០០នាក់ និងទិវាស្បៀងអាហារពិភពលោកនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន** ដែលមានសមាសភាពចូលរួមជាង ៦០០នាក់។

## ១២ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១២.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន ៨៥៨នាក់ (ស្ត្រី ៣០៦នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦០៦នាក់(ស្ត្រី ២១១នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ២២១នាក់(ស្ត្រី ៩៥នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការធានាគុណភាពអប់រំនៅសាលាជាតិកសិកម្មព្រែកលៀបលើកទី២" នៅសណ្ឋាគារមណ្ឌលគិរី ខេត្តមណ្ឌលគិរី និងពង្រឹងគុណភាពអប់រំ ឆ្ពោះទៅរកលក្ខណវិនិច្ឆ័យទាំង៩ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បាននិងកំពុង ពិនិត្យកែតម្រូវកម្មវិធីសិក្សាឲ្យឆ្លើយតបនឹងបទដ្ឋានជាតិ និងថ្នាក់តំបន់

- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី៤ លើកទី១២ ដែលជាការប្រជុំក្រុមប្រឹក្សាភិបាលចុងអណត្តិ ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសតំណាងមន្ត្រីរាជការ និងរៀបចំស្នើបំពេញតួនាទីដែលនៅទំនេរ

- បានរៀបចំពិធីប្រគល់ទទួលមន្ទីរពិសោធន៍ និងសម្ភារការិយាល័យនិងផ្ទះបាយ ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកអគ្គរដ្ឋទូតចិន

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ដល់សិក្ខាកាមមកពីរាជធានី- ខេត្តទាំង២៥

- បាននិងកំពុងអនុវត្តគម្រោងជួសជុលអគារសិក្សាចំនួន ០២ខ្នង និងការរៀបចំសាងសង់អាហារដ្ឋានមួយខ្នង

- បានបន្តរៀបចំពិសោធដំណាំស្រូវជប៉ុនវគ្គទី៧ និងការពិសោធន៍ជាមួយកសិករ នៅតាមបណ្តាខេត្តមួយចំនួនលើការដាំដុះដំឡូងផ្កាពូជជប៉ុន

- បាននិងកំពុងរៀបចំកន្លែងពិសោធន៍ត្រីសម្រាប់ការអនុវត្តជាក់ស្តែងរបស់និស្សិត។

### ១២.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន ៧៨១នាក់(ស្ត្រី ៣១៦នាក់) រួមមានៈ និស្សិតអាហារូបករណ៍សរុប ៥៧២នាក់ (ស្ត្រី ២៦៩នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្ត្រី ៤៧នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍

- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន ព្រមទាំងជាមួយទីភ្នាក់ងារ KOICA និង JICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យ ០២រូប ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ និងជប៉ុន

- បានទទួលជួបលោក MATSUDA Masahiro តំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម

- បានទទួលជួបតំណាង JICA ពិភាក្សាពីការរៀបចំគម្រោងកសិកម្មសរីរាង្គ គម្រោងស្រាវជ្រាវ គម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម ព្រមទាំងបានសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលស្តីពីកាកសំណល់រឹង និងភាវនៅទីសត្តឃាតដ្ឋានដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វចំនួន ២០នាក់

- បានរៀបចំពិធីប្រគល់សញ្ញាបត្រដល់និស្សិតសរុបចំនួន ៣១៨នាក់ (នារីចំនួន ៨៥នាក់)។

### ១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតសិក្សានាឆ្នាំសិក្សាថ្មី២០១៦-២០១៧នេះ មាននិស្សិតសរុបចំនួន ៣ ១០០នាក់ ចែកចេញជា១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- សាស្ត្រាចារ្យនិងនិស្សិតចំនួន ១០០នាក់បានចូលរួមធ្វើបទបង្ហាញផ្ទាល់មាត់និងតាមរយៈប៉ុស្ទ័រ នៅក្នុងអង្គសន្និសីទវិទ្យាសាស្ត្រថ្នាក់ជាតិលើកទី៣ ស្តីពីកសិកម្មនិងអភិវឌ្ឍន៍ជនបទនៅសាកលវិទ្យាល័យស្វាយរៀង និងបានចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងដែលរៀបចំដោយអគ្គនាយកដ្ឋានឧត្តមសិក្សានៅក្នុងខេត្តសៀមរាប

- បានសហការជាមួយក្រុមហ៊ុន SATAKE និងលោកស្រីបណ្ឌិត SAIYO KYOKO អតីតអ្នកជំនាញការJICA ប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម បានបើកវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យគុណភាពអង្ករ ដោយប្រើប្រាស់ឧបករណ៍ Grain Scanner ជូនដល់សិក្ខាកាមមកពីអង្គភាពផ្សេងៗ ក្រសួងមន្ទីរពាក់ព័ន្ធ សាស្ត្រាចារ្យ និងនិស្សិតចំនួន ១៣០នាក់ ដើម្បីស្វែងយល់ពីបច្ចេកវិទ្យាថ្មីលើការពិនិត្យគុណភាពគ្រាប់ធញ្ញជាតិ

- សាស្ត្រាចារ្យ និងនិស្សិតមហាវិទ្យាល័យវិស្វកម្មកសិកម្មបានចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ការយល់ដឹងលើការប្រើប្រាស់ឋាមពលនុយក្លេអែរនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ និងមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វបានចុះធ្វើកម្មសិក្សានៅខេត្តសៀមរាប កណ្តាល និងខេត្តកោះកុង។ សាលាបានទទួលនិងដំឡើងឧបករណ៍និងសម្ភារពិសោធន៍នៅក្នុងអគារមន្ទីរពិសោធន៍មីក្រូជីវវិទ្យាតាមរយៈគម្រោង SPS-ADB ដែលមកដល់ពេលនេះបានចំនួនប្រមាណ ៥០% ហើយ

- បានសហការជាមួយអង្គការ UNIDO ដើម្បីបង្កើតមជ្ឈមណ្ឌលព័ត៌មានបច្ចេកទេសជីវឧស្ម័នខ្នាតធំមួយនៅក្នុងសាកលវិទ្យាល័យ។ ក្រុមការងារសាកលវិទ្យាល័យបានបញ្ចប់ការងារ ចងក្រងវចនានុក្រមកសិកម្ម អង់គ្លេស-ខ្មែរ ក្រោមការជួយឧបត្ថម្ភគាំទ្រពីគម្រោង ACIA

- មន្ត្រី សាស្ត្រាចារ្យសាកលវិទ្យាល័យទាំងអស់ បានប្រជុំបូកសរុបលទ្ធផលការងាររយៈពេល៣ឆ្នាំ របស់សាកលវិទ្យាល័យ ក្នុងអាណត្តិក្រុមប្រឹក្សាភិបាលលើកទី៤ ឆ្នាំ២០១៤-២០១៦។ ចំពោះការងារសង្គម សាកលវិទ្យាល័យបានដឹកនាំនិស្សិតចំនួន ៥០០នាក់ ចូលរួមពិធីបើកការប្រកួតកីឡានៅពហុកីឡដ្ឋានជាតិអូឡាំពិក។

## III-បញ្ហាប្រឈម

ជាមួយនឹងសមិទ្ធផលដែលទទួលបានជាវិជ្ជមានដូចបានរៀបរាប់ខាងលើ ការអភិវឌ្ឍវិស័យកសិកម្មក៏ជួបប្រទះនូវចំណុចខ្វះខាតដែលត្រូវកែលម្អ និងបញ្ហាប្រឈមមួយចំនួនទៀតមានជាអាទិ៍៖ (១). កង្វះធនធានក្នុងការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ការបង្កើនផលិតភាពលើសក្តានុពលដីធ្លី ស្រែចម្ការរបស់កសិករ។ (២). ការបន្សាំរបស់កសិករទៅនឹងការប្រែប្រួលធាតុអាកាស ការផ្សព្វផ្សាយបច្ចេកទេសតាមផ្នែកនីមួយៗ រួមទាំងការផ្តល់ព័ត៌មានទីផ្សារកសិផលឱ្យបានទៅដល់កសិករនៅមានកម្រិត។ (៣). ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មឱ្យចំគោលដៅ និងសក្តានុពលភាពនៅតាមភូមិសាស្ត្រនីមួយៗស្ថិតនៅតែជាបញ្ហាដែលក្រសួងកំពុងគិតគូរអំពីការកំណត់តំបន់ដាំដុះឱ្យបានសមស្រប។ (៤). ប្រព័ន្ធស្រោចស្រពនៅពុំទាន់បានគ្របដណ្តប់លើផ្ទៃដីដាំដុះឱ្យបានទូលំទូលាយ ពិសេសការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ។ (៥). តម្លៃកសិផលធ្លាក់ចុះនៅក្នុងបរិបទនៃទីផ្សារសាកលពិសេសក្នុងកាលៈទេសៈដែលកសិករកំពុងប្រមូលផលស្រូវដើមរដូវវស្សា ចុងរដូវវស្សា និងរដូវប្រាំងនេះ។ (៦). សមត្ថភាពរបស់សហគមន៍កសិកម្ម ដែលជាតួអង្គសេដ្ឋកិច្ចនៅជនបទ និងលទ្ធភាពទទួលសេវាផ្សព្វផ្សាយកសិកម្មនៅមានកម្រិតនៅឡើយ។ (៧). សមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្មសមស្របតាមបទដ្ឋានបច្ចេកទេសក៏ដូចជាក្នុងការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិតដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ជាងតម្លៃកសិផលនៅលើទីផ្សារ។ (៨.) បទល្មើសព្រៃឈើ ជលផល ការលួចនាំចូលសត្វ និងសម្ភារកសិកម្មដោយខុសច្បាប់ នៅតែកើតមាន ពិសេសខេត្តនៅជាប់ព្រំដែន។ (៩.) សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើដោយខុសច្បាប់គឺនៅតែកើតមានពុំចេះចប់រហូតមកទល់បច្ចុប្បន្ននេះ។ (១០.) ការអនុវត្តថវិកាកម្មវិធីក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពជំនាញក្រោមឱវាទនៅមានកម្រិត។ (១១.) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការកែទម្រង់រដ្ឋបាលសាធារណៈ និងសេវាសាធារណៈពុំទាន់បានល្អប្រសើរតាមការរំពឹងទុក។

## IV-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយដោយសម្រេចបាន ១០៤,៩៧% លើសឆ្នាំមុនចំនួន ៣៧ ៦២៨ហ.ត (ស្មើនឹង ៥,១៧%)។ រីឯការងារប្រមូលផលដំណាំរដូវវស្សា ប្រជាកសិករបាននិងកំពុងជំរុញយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ៨៩,០៨% នៃផ្ទៃដីអនុវត្ត ២ ៥៩៩ ៥៨៦ហ.ត។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវប្រាំង ដោយគិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹង

នេះ ក៏បានជំរុញចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក ស្រោចទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ក្នុងកាលៈទេសៈដែលកសិករកំពុងប្រមូលផលស្រូវស្រាលដើមរដូវវស្សានេះក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារ ដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរ។ ករណីនេះ ក្រសួងបានយកចិត្តទុកដាក់បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន រួមទាំងសហគមន៍កសិកម្មផងដែរក្នុងក្របខ័ណ្ឌក្រុមការងារទី៩ ដែលបានឯកភាពគ្នាក្នុងអង្គប្រជុំកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅនេះ ដើម្បីរិះរកវិធានការតាមភារកិច្ចក្នុងការចូលរួមដោះស្រាយរាល់បញ្ហាប្រឈមលើការធ្លាក់ចុះតម្លៃស្រូវអង្ករនៅមូលដ្ឋាន។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ តាក់តែងច្បាប់និងបទដ្ឋានផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ។ ជាមួយគ្នានេះ ក្រសួងក៏បានជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បី ចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស បន្តយកចិត្តទុកដាក់ពង្រឹងការផ្ទេរមុខងាររបស់ខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទៅថ្នាក់ក្រោមជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការតាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

## V- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦-២០១៧

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវទាន់ពេលវេលា ចាត់ចែងជាបន្ទាន់ក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ព្រមទាំងកំពុងរៀបចំចាត់មន្ត្រីជំនាញ ដើម្បីត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូលឱ្យបានសមស្របតាមវិធានបច្ចេកទេស និងនីតិវិធីដោយអនុលោមតាមស្មារតីនៃលិខិតលេខ៩៤២ សជណ.កស ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងមាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មតចត់នូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទជាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំ

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ព្រមទាំងជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រតាមការចាំបាច់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទ ការចុះពង្រឹងភារកិច្ចក្នុងការបញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ត្រៀមរៀបចំវេទិកាស្វែងយល់ពីការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រកដំណោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដូចបានរៀបរាប់ខាងលើ ព្រមទាំងរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ និងការផលិតសម្រាប់នាំចេញដើម្បីឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី ស្តីទី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យុន្ឋ ភូថង**